## 1. ការចុះឈ្មោះធានារ៉ាប់រងសុខភាពជាតិដោយស្វ័យប្រវត្តិសម្រាប់ជនបរទេស កាតព្វកិច្ចចុះឈ្មោះក្នុងធានារ៉ាប់រងសុខភាពសម្រាប់ជនបរទេស

**គោលដៅដែលត្រូវចុះឈ្មោះ**
អ្នកចុះឈ្មោះតាមក្រុមហ៊ុន៖ បុគ្គលដែលបានចុះឈ្មោះជាជនបរទេស និងធ្វើការនៅកន្លែងធ្វើការ ដែលមានធានារ៉ាប់រងសុខភាព។
អ្នកចុះឈ្មោះតាមតំបន់៖ ជនបរទេសដែលបានរស់នៅក្នុងប្រទេសកូរ៉េលើសពី៦ខ
※ (ករណីលើកលែង) សម្រាប់ជនបរទេសដែលចូលប្រទេសកូរ៉េកាន់ទិដ្ឋាការជាជនរៀបការអន្តោប្រវេសន៍(F-6) ឬនិស្សិតបរទេស ត្រូវធ្វើការចុះឈ្មោះធានារ៉ាប់រងភ្លាមៗនៅពេលចូលមក ដល់ប្រទេសកូរ៉េ ។
**ការគណនាថ្លៃសេវាធានារ៉ាប់រង** ជនបរទេសដែលធ្វើការក្នុងក្រុមហ៊ុន៖ ចុះឈ្មោះនៅកន្លែងធ្វើការ។
ករណីមានប្ដីឬប្រពន្ធដែលធ្វើការនៅក្រុមហ៊ុន៖ ចុះឈ្មោះជាអ្នកពឹងផ្អែកលើធានារ៉ាប់រងសុខភាពរបស់ប្ដី ឬប្រពន្ធ
ករណីទាំងប្ដីប្រពន្ធជនជាតិកូរ៉េ ឬជនបរទេសមិនធ្វើការ៖ ករណីបើកអាជីវកម្មផ្ទាល់ខ្លួន ឬធ្វើការជាកម្មករប្រចាំថ្ងៃ អាចចុះឈ្មោះធានារ៉ាប់រងសុខភាពតាមតំបន់

※ក្នុងករណីចុះឈ្មោះតាមតំបន់ សូមសាខាដែលនៅជិតបំផុតដើម្បីចុះឈ្មោះ/ប្រឹក្សាយោបល់។(☎1577-1000)
※ជនបរទេសនឹងបាត់បង់សុពលភាពធានារ៉ាប់រង ប្រសិនបើស្នាក់នៅក្រៅប្រទេសកូរ៉េលើសពី១ខែ
**ការគណនាថ្លៃសេវាធានារ៉ាប់រង** ថ្លៃធានារ៉ាប់រងត្រូវបានគណនាដោយចំនួនគ្រួសារ តាមទ្រព្យសម្បត្តិ ចំណូលជាដើម តែក្នុងករណីថ្លៃធានារ៉ាប់រងមិនដល់ថ្លៃធានារ៉ាប់រងមធ្យមរបស់អ្នកចូលរួមនៅ ខែ១១ឆ្នាំមុន នោះឲ្យបង់ថ្លៃធានារ៉ាប់រងមធ្យមរហូតដល់ថ្ងៃទី១ខែ១ដល់ថ្ងៃទី៣១ខែ១២នៅឆ្នាំបន្ទាប់។
*ថ្លៃធានារ៉ាប់រងសុខភាពជាមធ្យមក្នុងឆ្នាំ២០២៤ ៖ ១៥០,៩៩០ វ៉ុន (រួមទាំងថ្លៃធានារ៉ាប់រងព្យាបាលរយៈពេលយូរសម្រាប់មនុស្សចាស់) ផ្អែកតាមថ្លៃសរុបនៃសមាជិកគ្រួសារ : គូស្រករ និងកូនអាយុក្រោម១៩ឆ្នាំដែលទីស្នាក់នៅជាមួយគ្នា។
※ទិដ្ឋការអចិន្ត្រៃយ៍(F-5), រៀបការអន្តោប្រវេសន៍(F-6): គិតថ្លៃធានារ៉ាប់រងស្មើគ្នានឹងប្រជាពលរដ្ឋកូរ៉េ
**បង់ថ្លៃធានារ៉ាប់រង** បង់ថ្លៃនៅខែបន្ទាប់ រហូតដល់ថ្ងៃទី២៥រាល់ខែ។
**ហួសកំណត់ថ្ងៃត្រូវបង់ថ្លៃសេវាធានារ៉ាប់រង** អត្ថប្រយោជន៍ធានារ៉ាប់រងសុខភាពមានកម្រិតនៅពេលប្រើប្រាស់មន្ទីរពេទ្យ និងគ្លីនិក។ កម្រិតលើការអនុញ្ញាតឱ្យស្នាក់នៅផ្សេងៗ ដូចជាការពន្យាទិដ្ឋាការសម្រាប់ជនបរទេស។
កំណត់ពេលវេលាបង់ប្រាក់ ហើយប្រសិនបើមិនបង់ និងរឹបអូសប្រាក់ចំណូល ទ្រព្យសម្បត្តិ ប្រាក់បញ្ញើជាដើម។
**ផលប្រយោជន** សេវាធានារ៉ាប់រងសុខភាពប្រជាពលរដ្ឋ មានផលប្រយោជន៍ដូចគ្នានឹងប្រជាពលរដ្ឋកូរ៉េ ដូចជាចូលដេកក្នុងមន្ទីរពេទ្យ ទទួលព្យាបាល ជម្ងឺធ្ងន់ ពិនិត្យសុខភាពជាដើម។

**ព័ត៌មានពីការចុះឈ្មោះ** សាជីវកម្មធានារ៉ាប់រងសុខភាពប្រជាពលរដ្ឋ (☎ 1577-1000)

## 2. សេវាកម្មថែទាំសុខភាពសម្រាប់ជនបរទេស ពិគ្រោះជម្ងឺផ្លូវចិត្តឥតគិតថ្លៃ

**ខ្លឹមសារនៃជំនួយ** ផ្ដល់ការពិគ្រោះ និងព្យាបាលវិបត្តិផ្លូវចិត្ត ដូចជាការបាក់ទឹកចិត្តបណ្ដាលមកពីវប្បធម៌ខុសគ្នាដោយឥតគិតថ្លៃ។

**ព័ត៌មានបន្ថែម** មជ្ឈមណ្ឌលសង្គមកិច្ចសុខភាពផ្លូវចិត្ត នៃខណ្ឌក្វាងសាន (☎ 062-941-8567)

## ជំនួយថ្លៃពេទ្យបន្ទាន់សម្រាប់ពលករបរទេស (រួមទាំងជនបរទេសដែលគ្មានឯកសារ)

**គោលដៅជំនួយ** ពលករបរទេស ស្វាមីភរិយា និងកូន(អាយុក្រោម ១៨ឆ្នាំ, ស្ត្រីរៀបការអន្តោប្រវេសន៍មុនចូលសញ្ជាតិ និងកូន(អាយុក្រោម ១៨ឆ្នាំ), ជនភៀសខ្លួន និងកូន(អាយុក្រោម ១៨ឆ្នាំ) ដែលមិនអាចទទួលផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ដូចជាសេវាធានារ៉ាប់រងសុខភាព

**ខ្លឹមសារនៃជំនួយ** ថ្លៃវេជ្ជសាស្ត្រ ដូចជាការចូលដេកក្នុងមន្ទីរពេទ្យ និងការវះកាត់ រាប់ចាប់ពីថ្ងៃចូល រហូតដល់ថ្ងៃចេញពីមន្ទីរពេទ្យ រហូតដល់៥លានវ៉ុនក្នុងមួយលើក

※ក្នុងករណីលើសពី ៥លានវ៉ុន ត្រូវការការពិភាក្សា និងលិខិតមូលហេតុ ពីស្ថាប័នវេជ្ជសាស្ត្រ

※ថ្លៃជំនួយនឹងផ្ដល់ត្រឹមតែ៩០% នៃថ្លៃព្យាបាលសរុបប៉ុណ្ណោះ រាប់ចាប់ពីថ្ងៃចូល រហូតដល់ថ្ងៃចេញពីមន្ទីរពេទ្យ (១០%ទៀត ត្រូវបង់ដោយអ្នកជំងឺ)

**របៀបចុះឈ្មោះ** អញ្ជើញទៅកាន់ ឬសាកសួរតាមទូរស័ព្ទនៅតាមស្ថាប័នមន្ទីពេទ្យដែលផ្ដល់ជំនួយ

**ស្ថាប័នមន្ទីរពេទ្យដែលផ្ដល់ជំនួយ**

| ស្ថាប័នមន្ទីរពេទ្យ | ទីតាំង | លេខទូរស័ព្ទ |
|---|---|---|
| មន្ទីរពេទ្យសកលវិទ្យាល័យឆនណាំ | ដុងហ្គូ ឆេគុងរ៉ូ ៤២(ហាក់ដុង) | ☎ 062-220-6908 |
| មន្ទីរពេទ្យគ្រិស្តឃ្វាំងជូ | ណាមហ្គូ យ៉ាងរីមរ៉ូ ៣៧(យ៉ាងរីមដុង) | ☎ 062-650-5597 |
| មន្ទីរពេទ្យសកលវិទ្យាល័យចូសន់ | ដុងហ្គូ ភីលមុនដេរ៉ូ ៣៦៥(សសក់ដុង) | ☎ 062-220-3677 |
| មន្ទីរពេទ្យឆង់ដាម | ក្វាងសានហ្គូ ឆង់ដាមដុងអាំងរ៉ូ ១៧០បន់ហ្គីល ៥៩ (សាំងអាមដុង) | ☎ 062-601-8140 |
| មន្ទីរពេទ្យភ្នែកបូរ៉ា | សហ្គូ សាំងមូចាយរ៉ូ ១៧០(ឈីផ្យង់ដុង) | ☎ 062-380-5826 |
| មន្ទីរពេទ្យភិតកូអឹលសកលវិទ្យាល័យឆនណាំ | ណាមហ្គូ ដក់ណាំហ្គីល៨០ (ដក់ណាំដុង) | ☎ 062-670-9445 |

**គោលការណ៍ជំនួយ** គោលការណ៍ការទូទាត់ក្រោយ។

**សាលាក្រុង** សាលាក្រុង Gwangju Metropolitan ផ្នែកជនបរទេស ក្រុមជំនួយជនអន្តោប្រវេសន៍(☎062-613-1642)

## ការព្យាបាលជម្ងឺឥតគិតថ្លៃសម្រាប់ជនអន្តោប្រវេសន៍

**គោលដៅ** ពលករអន្តោប្រវេសន៍,ជនភៀសខ្លួន,កូនចូលប្រទេសតាមក្រោយ, គ្រួសាររបស់ស្ត្រីអន្តោប្រវេសន៍ ដលែមិនបានទទួលផលប្រយោជន៍ខាងវេជ្ជសាស្ត្រ។

**ប្រភេទការព្យាបាល** ផ្នែកពេទ្យសាស្ត្រ,ផ្នែកពេទ្យបុរាណកូរ៉េ,ផ្នែកធ្មេញ,ផ្នែកថ្នាំពេទ្យ, ទន្តបណ្ឌិត, សម្ភព និងរោគស្ត្រី, ឱសថស្ថាន ការប្រឹក្សាខាងផ្លូវចិត្ត។

**ម៉ោងព្យាបាល** រៀងរាល់ថ្ងៃអាទិត្យ ម៉ោង 1:00 រសៀល ដល់ 5:00 ល្ងាច

**ព័ត៌មានបន្ថែម** សាលាក្រុង Gwangju Metropolitan ផ្នែកជនបរទេស ក្រុមជំនួយជនអន្តោប្រវេសន៍( ☎ 062-956-3353)

## ការគាំទ្រពីការចុះថ្លៃសម្រាលកូននិងថ្លៃសម្ភព

**គោលដៅ** ស្ត្រីអន្តោប្រវេសន៍ស្នាក់នៅក្នុងខណ្ឌ ដែលមិនដែលទទួលផលប្រយោជន៍ពីសេវាធានារ៉ាប់រងសុខភាព។

**ខ្លឹមសារនៃការគាំទ្រ** បញ្ចុះថ្លៃសម្រាលកូន និងថ្លៃព្យាបាលនៅផ្នែកសម្ភព។

**ព័ត៌មានបន្ថែម** គ្រួសារដែលមានជនជាតិខុសគ្នា ម៉ូជីហ្គេ (☎ 062-951-7993)



# 04 សម្ភព និងការថែទាំកុមារ

## 1. ការណែនាំពីជំនួយពេលមានផ្ទៃពោះ និងសម្រាលកូន

### ☑ មុនពេលមានផ្ទៃពោះ

### ជំនួយលើការពិនិត្យសុខភាពសម្រាប់ប្ដីប្រពន្ធថ្មី

**ជនមានសិទ្ធិទទួលជំនួយ៖** គូស្វាមីភរិយា១០០គូមកដំបូង ដែលបានរៀបការក្នុងរយៈពេល២ឆ្នាំ និងគូស្វាមីភរិយានឹងរៀបការ (ពលរដ្ឋខណ្ឌក្វាងសាន់) (គូស្វាមីភរិយាបរទេសដែលរស់នៅខណ្ឌក្វាងសាន់ក៏អាចទទួលជំនួយបានដែរ)

**ជំនួយដែលអាចទទួលបាន៖** ពិនិត្យជាតិស្ករក្នុងឈាម ជំងឺរលាកថ្លើមប្រភេទB ស្វូច រោគស្វាយ ជំងឺអេដស៍ ជំងឺរបេង ជម្ងឺស្លេក

**ទីតាំងដាក់ពាក្យ៖** មជ្ឈមណ្ឌលសុខភាពសាធារណៈខណ្ឌក្វាងសាន់

**ឯកសារចាំបាច់ភ្ជាប់ជាមួយ៖** អត្តសញ្ញាណប័ណ្ណជនបរទេស ឬសំបុត្រអាពាហ៍ពិពាហ៍ ឬលិខិតអញ្ជើញអាពាហ៍ពិពាហ៍ ឬកិច្ចសន្យាជួលកន្លែងរៀបអាពាហ៍ពិពាហ៍

**សាកសួរព័ត៌មាន៖** ផ្នែករដ្ឋបាលសុខាភិបាល ក្រុមជំនួយផ្នែកវេជ្ជសាស្ត្រ (☎ 062-960-8775)

### ជំនួយថ្លៃព្យាបាលសម្រាប់គូស្វាមីភរិយាគ្មានកូន

**ជនមានសិទ្ធិទទួលជំនួយ៖** គ្រួសារដែលមានប្រាក់ចំណូលក្រោម១១៨០% នៃប្រាក់ចំណូលមធ្យម (រួមទាំងគូស្វាមីភរិយាមិនបានចុះអាពាហ៍ពិពាហ៍តាមច្បាប់)

**ជំនួយដែលអាចទទួលបាន៖** ជំនួយចំនួន២១ដង (សិប្បនិម្មិត៩ដង, បង្កក៧ដង, ស្រស់៥ដង)

**ទីតាំងដាក់ពាក្យ៖** បន្ទាប់ពីសាកសួរតាមទូរស័ព្ទ សូមដាក់ពាក្យដោយផ្ទាល់នៅមជ្ឈមណ្ឌលទ្រទ្រង់ការរស់នៅស៊ូវ៉ាន់ ឬដាក់ពាក្យតាមអ៊ីនធឺណិត (Government 24)

**សាកសួរព័ត៌មាន៖** មជ្ឈមណ្ឌលទ្រទ្រង់ការរស់នៅស៊ូវ៉ាន់ ក្រុមការងារសុខភាពមាតា និងទារក (☎ 062-960-8756)

### ជំនួយបន្ថែមសម្រាប់គូស្វាមីភរិយាគ្មានកូន (ទីក្រុងក្វាងជូ)

**ជនមានសិទ្ធិទទួលជំនួយ៖** គូស្វាមីភរិយាគ្មានកូន ដែលបានរស់នៅខណ្ឌក្វាងសាន់លើសពី១ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យ (បុគ្គល ដែលធានារ៉ាប់រងសុខភាពការព្យាបាលគ្មានកូន អស់សុពលភាព)

**ជំនួយដែលអាចទទួលបាន៖** រហូតដល់៤ដងក្នុងមួយឆ្នាំ ជំនួយតាមកម្រិត និងប្រភេទនៃការព្យាបាល (រហូតដល់ ១.៥លានវ៉ុន)

**សាកសួរព័ត៌មាន៖** មជ្ឈមណ្ឌលទ្រទ្រង់ការរស់នៅស៊ូវ៉ាន់ ក្រុមការងារសុខភាពមាតា និងទារក

### ☑ ពេលមានផ្ទៃពោះ

### ការគាំទ្រថ្លៃព្យាបាលពេលមានផ្ទៃពោះនិងសម្រាលកូន(កាតសុភមង្គល គូកមីន)

**គោលដៅ** ជនដែលមានធានារ៉ាប់រងសុខភាព ឬជនដែលនៅជាមួយ ដែលបញ្ជាក់ពីការមានផ្ទៃពោះ និងការសម្រាលកូន(រួមទាំងការរលូតកូន)

**ប្រាក់ឧបត្ថម្ភ** ទារកនៅលីវ 1 លានវ៉ុន ទារក 2 នាក់ 2 លានវ៉ុន ទារក 3 នាក់ 3 លានវ៉ុន ទារក 4 នាក់ 4 លានវ៉ុន (បន្ថែមដើម្បីធ្វើឱ្យវា 1 លានវ៉ុនសម្រាប់ទារកម្នាក់)

**រយៈពេលឧបត្ថម្ភ** ២ឆ្នាំគិតចាប់ពីថ្ងៃចេញប័ណ្ណទូទាត់ ~ ថ្ងៃខែឆ្នាំកំណើត (រលូតកូន, កំណើតមិនទាន់កើត)

**របៀបសុំពាក្យ** សុំនៅធនាគារដែលអាចប្រើប្រាស់កាតសុភមង្គលគូកមីនបាន,សាជីវកម្មធានារ៉ាប់រងសុខភាព, បុកជីរ៉ូ(www.bokjiro.go.kr)

**កាតចេញផ្សាយ** កាតBC(☎ 1899-4651) កាត សាមសឹង(☎ 1566-3336) កាតរ៉ូតិ(☎ 1899-4282), កាតស៊ីនហាន់ (☎ 1544-8868), កាតKBគុកមីន(☎ 1599-7900)

**ព័ត៌មានបន្ថែម** សាជីវកម្មធានារ៉ាប់រងសុខភាពប្រជាពលរដ្ឋ (☎ 1577-1000 / www.nhis.or.kr)

## ឧបត្ថម្ភ FOLIC ACIDនិងជាតិដែកឲ្យស្ត្រីមានផ្ទៃពោះ

**គោលដៅ** ស្ត្រីមានផ្ទៃពោះដែលបានចុះឈ្មោះនៅមណ្ឌលសុខភាព។
**ខ្លឹមសារនៃការផ្តល់ផ្គង់** ឧបត្ថម្ភFOLIC ACID( ពេលមានផ្ទៃពោះដំបូង~12សប្តាហ៍ ) / ឧបត្ថម្ភថ្នាំជាតិដែក ( មានផ្ទៃពោះចាប់ពី១៦សប្តាហ៍ រហូតដល់ថ្ងៃសម្រាល )
**របៀបចុះឈ្មោះ** ៖ ដាក់ពាក្យដោយផ្ទាល់នៅមជ្ឈមណ្ឌលទ្រទ្រង់ការរស់នៅស៊ូវ៉ាន់ និងតាមមជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលប្រចាំសង្កាត់( ភ្ជាប់អត្តសញ្ញាណប័ណ្ណ ) ឬដាក់ពាក្យតាមអ៊ីនធឺណិត៖ Government 24 https://www.gov.kr
**ព័ត៌មានបន្ថែម** ក្រុមសុខភាពមាតា និងទារក ឬមជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ស៊ូវ៉ាន់ ( ☎ 062-960-8757 )

## កម្មវិធីថ្នាក់សុខភាពស្ត្រីមានផ្ទៃពោះ

**លម្អិតនៃកម្មវិធី៖** ថ្នាក់គ្រប់គ្រងអាហារូបត្ថម្ភអំឡុងពេលមានផ្ទៃពោះ ថ្នាក់បំបៅដោះកូន និងថ្នាក់បង្កើតផលិតផលថែទាំកុមារ, ថ្នាក់បង្ការ និងគ្រប់គ្រងជំងឺធ្លាក់ទឹកចិត្តក្រោយសម្រាល
**របៀបដាក់ពាក្យ៖** ចូលទៅគេហទំព័រការរៀនសូត្រពេញមួយជីវិតរបស់ខណ្ឌក្វាងសាន់ ហើយដាក់ពាក្យចូលរៀន
**សាកសួរព័ត៌មាន៖** មជ្ឈមណ្ឌលទ្រទ្រង់ការរស់នៅស៊ូវ៉ាន់ ក្រុមការងារសុខភាពមាតា និងទារក ( ☎ 062-960-8814, 8763 )

## ☑ ក្រោយសម្រាលកូន

## ប្រាក់ឧបត្ថម្ភជួបដំបូង

**លក្ខខណ្ឌតម្រូវ៖** ទារកដែលកើតក្រោយ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២ ដែលត្រូវបានចុះបញ្ជីស្នាក់នៅ។
**ប្រាក់ឧបត្ថម្ភ** 2លានវ៉ុនសម្រាប់កូនដំបូង, សម្រាប់ទារកដែលកើតមកមានកូនទីពីរ ឬច្រើនជាងនេះ។ ប័ណ្ណតម្លៃ 3 លានវ៉ុន ( ការចេញប័ណ្ណសុភមង្គលជាតិ )
**របៀបដាក់ពាក្យ៖** ( ទៅដោយផ្ទាល់ )មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលសង្កាត់, ( អនឡាញ ) Government 24, គេហទំព័រសុខុមាលភាព
**រយៈពេលប្រើប្រាស់៖** ១ឆ្នាំគិតចាប់ពីថ្ងៃខែឆ្នាំកំណើតរបស់កុមារ ( ថ្ងៃចុះឈ្មោះស្នាក់នៅ )
**ព័ត៌មានបន្ថែម៖** ក្រុមការងារគោលនយោបាយស្ត្រី នាយកដ្ឋានស្ត្រី និងកុមារ ក្វាងសានគូ ( ☎ 062-960-3605 )

## ប្រាក់ឧបត្ថម្ភអបអរមានកូនលើសពី១

**លក្ខខណ្ឌតម្រូវ៖** គ្រួសារដែលឪពុក ឬម្តាយមានចុះឈ្មោះទីលំនៅនៅទីក្រុងក្វាងជូ ចាប់ពី៣ខែឡើង ពីថ្ងៃសម្រាលកូន
**ចំនួនទឹកប្រាក់ឧបត្ថម្ភ៖** ១លាន៤សែនវ៉ុន នៅពេលសម្រាលបានទារកភ្លោះឡើងទៅ
**របៀបដាក់ពាក្យ៖** ( ទៅដោយផ្ទាល់ )មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលសង្កាត់, ( អនឡាញ ) Government 24, គេហទំព័រសុខុមាលភាព
**សាកសួរព័ត៌មាន៖** ខណ្ឌក្វាងសាន់ ផ្នែកស្ត្រី និងកុមារ ក្រុមគោលនយោបាយមិត្តភាពស្ត្រី ( ☎ 062-960-3605 )

## ប្រាក់លើកទឹកចិត្តសម្រាលកូនទីបី ឬច្រើនជាងនេះ

**ជនមានសិទ្ធិទទួលជំនួយ៖** គ្រួសារដែលមានកូនទីបី ឬច្រើនជាងនេះ និងមានអាសយដ្ឋាននៅខណ្ឌក្វាងសាន់
**ចំនួនទឹកប្រាក់ឧបត្ថម្ភ៖** កូនទី៣ : 45ម៉ឺនវ៉ុន/ កូនទី៤ : 100ម៉ឺនវ៉ុន/ លើសកូនទី៥ : ម៉ឺនវ៉ុន
**របៀបដាក់ពាក្យ៖** មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលសង្កាត់
**សាកសួរព័ត៌មាន៖** ខណ្ឌក្វាងសាន់ ផ្នែកស្ត្រី និងកុមារ ក្រុមគោលនយោបាយមិត្តភាពស្ត្រី ( ☎ 062-960-3605 )



## សេវាក
## ម្មជួយម្តាយដែលបានសម្រាលកូន

**គោលដៅ** គ្រួសារដែលជនជាតិខុសគ្នា/ស្ត្រីរៀបការអន្តោប្រវេសន៍ដែលបានរស់នៅនិងចុះឈ្មោះនៅក្រុងក្វាងជូ/ស្ត្រីមានផ្ទៃពោះជនជាតិកូរ៉េ។
**រយៈពេលសម្រាប់សុំពាក្យ** ចាប់ពីមានផ្ទៃពោះបាន៨ខែ រហូតដល់៩០ថ្ងៃ ក្រោយសម្រាលកូន។
**ថ្លៃសេវា** ឥតគិតថ្លៃ
**ឥតគិតថ្លៃ** អ្នកជំនួយជាស្ត្រីអន្តោប្រវេសន៍នឹងទៅដល់ផ្ទះ ថែនិងចិញ្ចឹមកូនដែលទើបកើត និងម្តាយសម្រាលកូន។
**ឯកសារសុំពាក្យ** ពាក្យសុំប្រើប្រាស់,កិច្ចសន្យា,លិខិតបញ្ជាក់កំណើត( សៀវភៅសម្រាប់ម្តាយសម្រាលកូននោះមិនបានទេ ) ឬលិខិតបញ្ជាក់ការមានផ្ទៃពោះ, ចម្លងកាតធានារ៉ាប់រងសុខភាព,លិខិតបញ្ជាក់បង់ថ្លៃសររាធានារ៉ាប់រងសុខភាព( ៦ខែថ្មីៗនេះ ), ចម្លងចុះឈ្មោះអ្នករស់នៅ( បញ្ជាក់ការចុះឈ្មោះនៅទីស្នាក់នៅ,កត់តែថ្ងៃខែឆ្នាំកំណើត ),លិខិតបញ្ជាក់គ្រួសារដែលជនជាតិខុសគ្នា( ជ្រើសរើស១ក្នុងចំណោមលិខិតចុះឈ្មោះជនបរទេស,លិខិតបញ្ជាក់ទាក់ទងគ្រួសារ, លិខិតរាយការណ៍ជនរួមជាតិដែលមានសញ្ជាតិបរទេស ដែលស្នាក់នៅក្នុងស្រុក។
**លេខទូរស័ព្ទ** មជ្ឈមណ្ឌលគ្រួសារ ខណ្ឌប៊ូក ក្វាងជូ ( ☎ 062-363-2963, 526-6004, 070-7834-6853 )

## ឧបត្ថម្ភការថែទាំសុខភាពរបស់ម្តាយទើបឆ្លងទន្លេ និងកូនទើបកើត

**គោលដៅ** ស្ត្រីរៀបការអន្តោប្រវេសន៍ជាម្តាយទើបឆ្លងទន្លេមានប្រាក់ចំណូលមធ្យមក្រោម១៥០ភាគរយ
**ថ្លៃសេវា** ថ្លៃសេវាទៅតាមចំណូលរបស់សាមីខ្លួន។
**ខ្លឹមសារនៃការឧបត្ថម្ភ** ផ្តល់ប័ណ្ណទូទាត់ប្រាក់សេវាថែទាំសុខភាពដល់ផ្ទះ ទៅដល់ម្តាយទើបឆ្លងទន្លេ និងកូនទើបកើត។ ឧបត្ថម្ភការដល់ការជ្រើសរើសរយៈពេលសេវាកម្ម ទៅតាមប្រភេទគត៌ និងលំដាប់កំណើតទារក( 5ថ្ងៃ~40ថ្ងៃ ) ថែទាំសុខភាពរបស់ម្តាយទើបឆ្លងទន្លេ•ទារកទើបកើត,គ្រប់គ្រងចំណីអាហារ, មុជទឹក, បោកខោអាវ, មើលថែកូនទើបកើត។
**លេខទូរស័ព្ទ** សូមទៅកាន់ មជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ស៊ូវ៉ាន់ បន្ទាប់ពីសាកសួរតាមទូរស័ព្ទ( ☎ 062-960-8757 )

## ការបន្ថែមចំណីអាហារសម្រាប់ស្ត្រីមានផ្ទៃពោះ និងទារក

**គោលដៅ** ស្ត្រីមានផ្ទៃពោះ និងទារក( អាយុក្រោម 6 ឆ្នាំ។ ) ដែលចំណីអាហារមិនគ្រប់ ឬកង្វះឈាម និងមានចំណូលមធ្យមក្រោម៨០ភាគរយ ( ៥,៨៤០,០០០វ៉ុនសម្រាប់ គ្រួសារសមាជិក៤នាក់ )
**ខ្លឹមសារនៃការឧបត្ថម្ភ** ផ្តល់អាហារបំប៉នបន្ថែម តាមស្ថានភាពចំណីអាហារម្នាក់ៗ
**លេខទូរស័ព្ទ** សូមទៅកាន់ មជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ស៊ូវ៉ាន់ បន្ទាប់ពីសាកសួរតាមទូរស័ព្ទ ( ☎ 062-960-8753, 8754 )

## កម្មវិធីជួលបូមទឹកដោះ ( អាចចុះឈ្មោះបានក្រោយពេលសម្រាល )

**ជនមានសិទ្ធិទទួលជំនួយ៖** ម្តាយដែលសម្រាលកូនរួច ឬកំពុងបំបៅដោះកូន មានអាសយដ្ឋាននៅក្នុងខណ្ឌ
**រយៈពេលជួល៖** ២ ខែ
**ឧបករណ៍សម្រាប់ជួល៖** តួសម្រាប់បូមទឹកដោះ ( Spectra S2+ ), ជើងត, កាបូបស្ពាយ, សៀវភៅណែនាំប្រើប្រាស់
※ សម្ភារៈផ្សេងៗ គឺជាសម្ភារៈអនាម័យ ដូច្នេះត្រូវទិញផ្ទាល់ខ្លួន
**ឯកសារភ្ជាប់ជាមួយ៖** អត្តសញ្ញាណប័ណ្ណ ច្បាប់ចម្លងនៃការចុះបញ្ជីស្នាក់នៅ ( សំបុត្រកំណើត )
**របៀបជួល៖** ធ្វើការកក់ទុកជាមុន បន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកនៅលើគេហទំព័រ របស់មជ្ឈមណ្ឌលសុខភាពសាធារណៈខណ្ឌក្វាងសាន់ ហើយមកយកវាដោយផ្ទាល់ ឬអ្នកតំណាងមកយកជំនួស ពេលដល់ពេលណាត់
※ ការជួលដោយផ្អែកលើប្រព័ន្ធកក់ទុកតាមលេខរៀង
**សាកសួរព័ត៌មាន៖** មជ្ឈមណ្ឌលទ្រទ្រង់ការរស់នៅស៊ូវ៉ាន់ ក្រុមការងារសុខភាពមាតា និងទារក ( ☎ 062-960-8814 )

## ឧបត្ថម្ភថ្លៃចាក់ថ្នាំបង្ការឲ្យកុមារ

**គោលដៅ** កុមារអាយុក្រោម ១២ឆ្នាំ (រួមទាំងកុមារបរទេសដែលមិនបានចុះឈ្មោះ)
*សម្រាប់ជនបរទេសដែលមិនបានចុះឈ្មោះ ជំនួយក្នុងការចាក់ថ្នាំបង្ការជាតិ អាចទទួលបាន បន្ទាប់ពីមណ្ឌលសុខភាពសាធារណៈបង្កើតលេខគ្រប់គ្រងបណ្ដោះអាសន្ន
*ឯកសារចាំបាច់សម្រាប់ការបង្កើតលេខគ្រប់គ្រងបណ្ដោះអាសន្ន៖ សំបុត្រកំណើត លិខិតឆ្លងដែន ឬលិខិតឆ្លងដែនរបស់ឪពុកម្ដាយ/អត្តសញ្ញាណប័ណ្ណជនបរទេស
**កន្លែងទទួលថ្នាំបង្ការ៖** មណ្ឌលសុខភាពសាធារណៈ និងស្ថាប័នវេជ្ជសាស្ត្រដែលបានកំណត់
**លេខទូរស័ព្ទ** ក្រុមគ្រប់គ្រងជំងឺឆ្លង មណ្ឌលសុខភាព ក្វាងសានគូ(☎ 062-960-8758)

## ការបញ្ចុះតម្លៃថ្លៃអគ្គិសនី ចំពោះគ្រួសារទើបសម្រាលកូន

**បុគ្គលដែលអាចចុះឈ្មោះ៖** គ្រួសារដែលមានសមាជិកលើសពីម្នាក់ និងមានទារកអាយុក្រោម៣ឆ្នាំ
**※ជនជាតិកូរ៉េនៅបរទេស និងគ្រួសារជនបរទេសអាចចុះឈ្មោះទីលំនៅរបស់ខ្លួនជាមួយនឹងរបាយការណ៍ស្ដីពីទីលំនៅក្នុងស្រុក និងអត្តសញ្ញាណប័ណ្ណសម្គាល់ជនបរទេស -ល- តាមច្បាប់**
**រយៈពេលសម្រាប់សុំពាក្យ** ចាប់ពីខែដាក់ពាក្យស្នើសុំ រហូតដល់ខែ ឆ្នាំទី៣នៃថ្ងៃខែឆ្នាំចាប់កំណើត។
**ខ្លឹមសារពីការសុំ** បញ្ចុះថ្លៃអគ្គិសនី៣០ភាគរយក្នុងមួយខែ (កំណត់ត្រឹម16,000វ៉ុនក្នុង១ខែ)
**របៀបសុំពាក្យ** គេហទំព័រ សាខាសាយប៊ើរ(cyber) អគ្គិសនីកូរ៉េ(http://cyber.kepco.co.kr/ckepco/), ការិយាល័យគ្រប់គ្រងអាផាតមិន,សាខាអគ្គិសនីកូរ៉េ(☎ 123)

## 2. ការណែនាំពីជំនួយក្នុងការចិញ្ចឹមកូន

## ថ្លៃសេវាចិញ្ចឹមនៅផ្ទះកុមារ(សាលាមត្តេយ្យ)

**គោលដៅ** ទារកដែលមានអាយុពី០-៥ឆ្នាំ ជាសញ្ជាតិកូរ៉េ ដែលដាក់នៅមជ្ឈមណ្ឌលថែទាំកុមារ ឬសាលាមត្តេយ្យ
**ចំនួនប្រាក់ឧបត្ថម្ភ** រដ្ឋាភិបាលឧបត្ថម្ភថ្លៃចិញ្ចឹម១០០ភាគរយតាមអាយុ។
**របៀបសុំពាក្យ** មជ្ឈមណ្ឌលសង្គមកិច្ចនិងរដ្ឋបាលនៅសង្កាត់ដែលកំពុងរស់នៅ។
**របៀបឧបត្ថម្ភ** បង់ថ្លៃមើលថែរៀងរាល់ខែ ដោយកាតសុភមង្គលកុមារ។
**លេខទូរស័ព្ទ** ក្រុមថែទាំកុមារប្រកបដោយការច្នៃប្រឌិត និងកុមារ ក្វាងសានគូ(☎ 062-960-8368)

## ជំនួយថ្លៃថែទាំកុមារ សម្រាប់កុមារដែលមានសញ្ជាតិបរទេស (មិនរាប់បញ្ចូលជនបរទេសដែលមិនបានចុះឈ្មោះ)

**ជនមានសិទ្ធិទទួលជំនួយ៖** កុមារដែលមានអាយុពី៣ទៅ៥ឆ្នាំ មានសញ្ជាតិបរទេស ដែលបញ្ជូនទៅមជ្ឈមណ្ឌលថែទាំកុមារ ឬសាលាមត្តេយ្យ
**ចំនួនទឹកប្រាក់ឧបត្ថម្ភ៖** រហូតដល់ 280,000 វ៉ុនក្នុងមួយខែ/ម្នាក់(ការដាក់ប្រាក់ទៅកន្លែងថែទាំកុមារ)
**របៀបចុះឈ្មោះ៖** មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលសង្កាត់(កន្លែងថែទាំកុមារដែលពាក់ព័ន្ធ)
**សាកសួរព័ត៌មាន៖** ខណ្ឌក្វាងសាន់ ផ្នែកស្ត្រី និងកុមារ ក្រុមថែទាំកុមារ (☎ 062-960-8367)



## ឧបត្ថម្ភប្រាក់សម្រាប់ថែទាំកុមារ ដែលមិនប្រើប្រាស់កន្លែងថែទាំកុមារ

**គោលដៅ** កុមារគ្រប់រូបមានអាយុក្រោម៨៦ខែ ដែលមិនទាន់ចូលបឋមសិក្សា និងត្រូវបានមើលថែនៅផ្ទះដោយមិនប្រើប្រាស់មជ្ឈមណ្ឌលថែទាំកុមារ សាលាមត្តេយ្យ ឬសេវាថែទាំកុមារ (ពេញមួយថ្ងៃ)
**ខ្លឹមសារនៃការឧបត្ថម្ភ** (ឧបត្ថម្ភសាច់ប្រាក់) 100,000 វ៉ុន សម្រាប់កុមារអាយុចន្លោះពី 24 ទៅ 86 ខែ។
※អនុលោមតាមការណែនាំច្បាប់អំពីប្រាក់បៀវត្សរបស់មាតាបិតា កុមារដែលកើតក្រោយឆ្នាំ២០២២ នឹងទទួលបានប្រាក់ឧបត្ថម្ភចាប់ពីអាយុ 2 ឆ្នាំ
**របៀបសុំពាក្យ** មជ្ឈមណ្ឌលសង្គមកិច្ចនិងរដ្ឋបាលនៅសង្កាត់ដែលកំពុងរស់នៅ។
**លេខទូរស័ព្ទ** ក្រុមថែទាំកុមារប្រកបដោយការច្នៃប្រឌិត និងកុមារ ក្វាងសានគូ(☎ 062-960-8368)

## ប្រាក់ខែរបស់ឪពុកម្ដាយ

**គោលដៅទូទាត់** ក្មេងអាយុក្រោម 2 ឆ្នាំ (0-23 ខែ) កើតក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2022
**ចំនួនទឹកប្រាក់ទូទាត់៖**
អាយុ 0 ឆ្នាំ: 1 លានវ៉ុនក្នុងមួយខែ (ប្រសិនបើប្រើកន្លែងថែទាំកុមារ ថ្លៃថែទាំកុមារត្រូវបានកាត់ ហើយភាពខុសគ្នាត្រូវបានបង់)
អាយុ 1 ឆ្នាំ: 500,000 វ៉ុនក្នុងមួយខែសម្រាប់ក្មេង (ប្រសិនបើប្រើកន្លែងថែទាំកុមារ ថ្លៃថែទាំកុមារត្រូវបានកាត់ ហើយភាពខុសគ្នាត្រូវបានបង់)
**ទីតាំងដាក់ពាក្យ៖**
ពាក្យសុំចូលមើល: មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលដែលមានយុត្តាធិការលើអាសយដ្ឋាន
កម្មវិធីអនឡាញ: គេហទំព័រ Bokjiro (www.bokjiro.go.kr)
**លេខទូរស័ព្ទ** ក្រុមថែទាំកុមារប្រកបដោយការច្នៃប្រឌិត និងកុមារ ក្វាងសានគូ(☎062-960-8368)

## ឧបត្ថម្ភថ្លៃចាក់ថ្នាំ

**គោលដៅ** កុមារអាយុក្រោម៧ឆ្នាំ សញ្ជាតិកូរ៉េ
**ខ្លឹមសារនៃការគាំទ្រ** (ផ្ដត់ផ្គង់សាច់ប្រាក់) ១០០,០០០វ៉ុន ក្នុងមួយខែ សម្រាប់កុមារម្នាក់
**របៀបសុំពាក្យ** សុំពាក្យនៅមជ្ឈមណ្ឌលសង្គមកិច្ចនិងរដ្ឋាបាលនៅសង្កាត់ដែលកំពុងរស់នៅ, សុំពាក្យតាមគេហទំព័របុកជីរ៉ូ។ (www.bokjiro.go.kr)
**លេខទូរស័ព្ទ** ក្រុមសុខុមាលភាពកុមារ និងកុមារ ក្វាងសានគូ(☎ 062-960-8456)

## សេវាកម្មមើលថែទារកាំ

**គោលដៅ** គ្រួសារដែលមានកូនអាយុពី៣ខែ ដល់១២ឆ្នាំ មានសញ្ជាតិកូរ៉េ
**ខ្លឹមសារនៃការគាំទ្រ** អ្នកថែទាំម្នាក់ទៅដល់ផ្ទះដើម្បីផ្ដល់សេវាថែទាំកុមារ ទៅដល់កុមារដែលត្រូវការជំនួយ និងឧបត្ថម្ភការចំណាយផ្សេងៗគ្នាទៅតាមចំណូលគ្រួសារ។
**របៀបសុំពាក្យ** គ្រួសារដែលរដ្ឋាភិបាលឧបត្ថម្ភ]មជ្ឈមណ្ឌលសង្គមកិច្ចនិងរដ្ឋបាលនៅសង្កាត់ដែលរស់នៅ,
ការដាក់ពាក្យសុំគេហទំព័រBokjiro(www.bokjiro.go.kr)
គ្រួសារដែលរដ្ឋាភិបាលមិនគាំទ្រ(ខ្លួនឯងជាអ្នកទទួលបន្ទុក)]គេហទំព័រ ថែកូន(www.idolbom.go.kr)
ស្ថាប័នផ្ដល់សេវាថែទាំកុមារ (☎ 062-959-9336)
**លេខទូរស័ព្ទ** ក្រុមគោលនយោបាយដែលរាក់ទាក់នឹងស្ត្រី និងកុមារ ក្វាងសានគូ(☎ 062-960-3605)

## ការថែទាំកុមារក្រៅម៉ោង នៅថ្ងៃសប្តាហ៍ ( 09:00-18:00 )

**តើការថែទាំកុមារក្រៅម៉ោងជាអ្វី?** សេវាថែទាំកុមារត្រូវបានប្រើប្រាស់នៅពេលដែលមានស្ថានភាពអាសន្ន ដូចជាកាលៈទេសៈ ឬគ្រោះថ្នាក់ដែលមិនអាចជៀសវាងបានរបស់អាណាព្យាបាល ឬនៅពេលដែលត្រូវការការថែទាំកុមារជាបណ្តោះអាសន្ន

**បុគ្គលអាចប្រើប្រាស់៖** ទារកអាយុពី៦ទៅ៣៦ខែ

**ពេលវេលាប្រើប្រាស់៖** ច័ន្ទ~សុក្រ 09:00~18:00 ( 60 ម៉ោងក្នុងមួយខែ )

**ថ្លៃឧបត្ថម្ភ៖** ៥,000 វ៉ុនក្នុងមួយម៉ោង ( ជំនួយរដ្ឋាភិបាល ៣,000វ៉ុន + បង់ដោយខ្លួនឯង ២,000វ៉ុន )

**ស្ថាប័នផ្តល់ជំនួយ៖** មជ្ឈមណ្ឌលថែទាំកុមារ មជ្ឈមណ្ឌលគាំពារកុមារដែលបានកំណត់

**របៀបប្រើប្រាស់៖** ( ចុះឈ្មោះតាមអនឡាញ ) វិបផតថលការថែទាំកុមារ និងស្រ្តីមានផ្ទៃពោះ ( www.childcare.go.kr ) ឬគេហទំព័រទូរស័ព្ទ ( m.childcare.go.kr )

※ ចុះឈ្មោះតាមអនឡាញ១ថ្ងៃមុនប្រើប្រាស់, ចំពោះការទូរស័ព្ទ ត្រូវតេចុះឈ្មោះត្រឹមម៉ោងពារសៀលនៅថ្ងៃចង់ប្រើប្រាស់

※ ក្នុងករណីចុះឈ្មោះប្រើប្រាស់បន្ទាន់នៅថ្ងៃដដែល អាចធ្វើឡើងបានលុះត្រាតែការចុះឈ្មោះជាសមាជិក ( ចុះឈ្មោះវិញ្ញាបនបត្រសាធារណៈ ) ជាមុននៅគេហទំព័រអាយសាវាង( PC ) ដែលជាវិបផតថលការថែទាំកុមារ និងស្រ្តីមានផ្ទៃពោះ

**សាកសួរព័ត៌មាន៖** ទីក្រុងក្វាងជូ មជ្ឈមណ្ឌលគាំពារកុមារ ( ☎ 062-714-3635 )

## មជ្ឈមណ្ឌលថែទាំកុមារបន្ទាន់ក្រុងក្វាងជូ ( ការថែទាំក្រៅម៉ោងពេលយប់ )

**បុគ្គលមានសិទ្ធិប្រើប្រាស់៖** ទារក និងកុមារអាយុពី ៦ខែ ដល់ ៥ឆ្នាំ

**ថ្លៃថែទាំ៖** ២,000វ៉ុនក្នុងមួយម៉ោង

**រយៈពេលជំនួយ៖** ៧ករណីក្នុងមួយខែ ឬ៨០ម៉ោងក្នុងមួយខែ

( ※ អាចប្រើប្រាស់បានដោយចំណាយថវិកាផ្ទាល់ខ្លួន៥,000វ៉ុនក្នុងមួយម៉ោង ប្រសិនបើប្រើប្រាស់លើស ៧ករណីក្នុងមួយខែ ឬ៨០ម៉ោងក្នុងមួយខែ )

**របៀបប្រើប្រាស់៖** ចុះឈ្មោះនៅលើគេហទំព័រ www.gjicare.or.kr បន្ទាប់មកចុះឈ្មោះកូន និងធ្វើការកក់ទុកការថែទាំបន្ទាន់

| បែងចែក | ពេលវេលាប្រើប្រាស់ | អាសយដ្ឋាន | លេខទូរស័ព្ទ |
|---|---|---|---|
| ខណ្ឌក្វាងសាន់ | ថ្ងៃច័ន្ទ - សុក្រ 18:00 - 9:00 ថ្ងៃបន្ទាប់<br>ថ្ងៃសៅរ៍ 9:00 - 20:00 | 광산구 첨단강변로 100, 110동 1,2층<br>(쌍암동, 힐스테이트 오피스텔) | ☎ 062-714-3635<br>( រូបចុចលេខ 2 ) |
| ខណ្ឌសគូ | ច័ន្ទ-សុក្រ 18:00-23:00<br>ថ្ងៃសៅរ៍ 9:00 - 20:00 | 서구 상무자유로 73,<br>일가정양립지원본부 2층<br>(구, 여성발전센터) | ☎ 062-375-0756<br>( រូបចុចលេខ 1 ) |

## ឧបត្ថម្ភថ្លៃព្យាបាលជម្ងឺហឺត

**គោលដៅ** ជនស្នាក់នៅខណ្ឌ ហ្វាង់សានដែលបានពិនិត្យថាមានជម្ងឺហឺត( J45-46 ) មានអាយុក្រោម១២ឆ្នាំ និងមានចំណូលមធ្យមក្រោម១២០ភាគរយ ។

**ខ្លឹមសារនៃការគាំទ្រ** សេវាព្យាបាល, ថ្លៃថ្នាំពេទ្យ ( កម្រិតត្រឹម២០ម៉ឺនវ៉ុនក្នុងម្នាក់ ក្នុង១ឆ្នាំ )

**លេខទូរស័ព្ទ** ក្រុមព្យាបាលជំងឺរ៉ាំរ៉ៃ មជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ស៊ូវ៉ាន់ ខណ្ឌហ្វាង់សាន ក្វាងសានគូ ( ☎ 062-960-8827, 8813 )

## ឧបត្ថម្ភប្រេងសម្រាប់ដំបៅអាថុតី

**គោលដៅ** កុមារងាយរងគ្រោះអាយុក្រោម១២ឆ្នាំ និងត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺរលាកស្បែក អាថុតី ( L20 )

**ឯកសារត្រូវការ៖** វិញ្ញាបនបត្រវេជ្ជសាស្រ្ត ឬវេជ្ជបញ្ជា និងឯកសារបញ្ជាក់ពីគ្រួសារពហុវប្បធម៌ -ល-

**ខ្លឹមសារនៃការគាំទ្រ** ឧបត្ថម្ភឧបត្ថម្ភប្រេងដែលធ្វើឲ្យស្បែកសើម( ថ្នាំរាវ ) ៣ខែ ១ដប។

**លេខទូរស័ព្ទ** ក្រុមព្យាបាលជំងឺរ៉ាំរ៉ៃ មជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ស៊ូវ៉ាន់នៃខណ្ឌហ្វាង់សាន ក្វាងសានគូ ( ☎ 062-960-8827, 8813 )



## ពិនិត្យសុខភាពសម្រាប់ទារក

**គោលដៅ** កុមារអាយុក្រោម៦ឆ្នាំ សញ្ជាតិកូរ៉េ

**ខ្លឹមសារនៃការគាំទ្រ** ឧបត្ថម្ភការចំណាយពេញថ្លៃលើការពិនិត្យសុខភាព( ៨លើក ), ពិនិត្យមាត់ធ្មេញ( ៣លើក )

**របៀបទទួលការពិនិត្យសុខភាព** សាជីវកម្មធានារ៉ាប់រងសុខភាពផ្ញើសេចក្តីណែនាំពីការពិនិត្យសុខភាពកុមារឲ្យគ្រួសារមានទារក → ទទួលការពិនិត្យនៅស្ថាប័នពិនិត្យ ដោយកាន់អត្តសញ្ញាណប័ណ្ណ,លិខិតពិនិត្យសុខភាព។

**លេខទូរស័ព្ទ** សាជីវកម្មធានារ៉ាប់រងសុខភាពប្រជាពលរដ្ឋ( ☎ 1577-1000 )

## ឧបត្ថម្ភកន្ទប និងម្សៅដោះគោសម្រាប់គ្រួសារដែលមានចំណូលទាប

**គោលដៅ** ទារកអាយុក្រោម២ឆ្នាំ( គ្រួសារដែល ធានាជីវភាពមូលដ្ឋាន ក្រីក្រ ឪពុកឬម្តាយទោល ពិការដែលមានប្រាក់ចំណូលមធ្យមក្រោម៨០% មានកូនច្រើន[ពីរ ឬច្រើន] )

**ខ្លឹមសារនៃការគាំទ្រ** ផ្គត់ផ្គង់ថ្លៃកន្ទប( ១ខែ ៨០,000វ៉ុន )/ឧបត្ថម្ភថ្លៃម្សៅដោះគោ និងអាហារជំនួសទឹកដោះគោ( ១០០,000វ៉ុន ) ក្រោយទារកកើត ឧបត្ថម្ភរហូតដល់២៤ខែ។

**លេខទូរស័ព្ទ** ក្រុមសុខភាពមាតា និងទារក សួរពីមជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ស៊ូវ៉ាន់ ខណ្ឌហ្វាង់សាន ( ☎ 062-960-8757 )

## ឧបត្ថម្ភភ្លុយអរ( fluoride )សម្រាប់កុមារ

**មនុស្សគោលដៅ** ទារក និងមានអាយុលើស36ខែ។

**ខ្លឹមសារនៃការគាំទ្រ** ការអប់រំពីសុខភាពមាត់ធ្មេញ, សារធាតុភ្លុយអរ។

**លេខទូរស័ព្ទ** ក្រុមសុខភាពមាត់ធ្មេញ មជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ខណ្ឌហ្វាង់សាន ក្វាងសានគូ ( ☎ 062-960-3813 )

## ការព្យាបាលធ្មេញរបស់កុមារ

**គោលដៅ** សិស្សបឋមសិក្សាដែលមានប្រាក់ចំណូលទាបក្រោម ១០០% នៃប្រាក់ចំណូលមធ្យមស្តង់ដារ។

**ខ្លឹមសារនៃការគាំទ្រ** ពិនិត្យព្យាបាលបង្ការ, ព្យាបាលក្នុងមាត់ធ្មេញ( ផ្គត់ផ្គង់ម្នាក់៥ម៉ឺនទៅដល់៤៥ម៉ឺនវ៉ុន )

**លេខទូរស័ព្ទ** ក្រុមសុខភាពមាត់ធ្មេញ មជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ខណ្ឌហ្វាង់សាន ក្វាងសានគូ ( ☎ 062-960-3813 )

## ការថែទាំសុខភាពមាត់ធ្មេញសម្រាប់កុមារពហុវប្បធម៌

**ជនមានសិទ្ធិទទួលជំនួយ៖** កុមារពហុវប្បធម៌

**ជំនួយដែលអាចទទួលបាន៖** ការអប់រំអំពីសុខភាពមាត់ធ្មេញ និងការចែកចាយទឹកខ្ពុរមាត់ដែលមានជាតិហ្លួយអូរីត ដល់កន្លែងកុមារពហុវប្បធម៌កំពុងសិក្សា

**លេខទូរស័ព្ទ** ក្រុមសុខភាពមាត់ធ្មេញ មជ្ឈមណ្ឌលគាំទ្រជីវភាពសុខភាពល្អ ខណ្ឌហ្វាង់សាន ក្វាងសានគូ ( ☎ 062-960-3812 )

## 3. ស្ថានភាពមជ្ឈមណ្ឌលថែទាំពិសេស និងរួមបញ្ចូលគ្នា សម្រាប់កុមារពិការនៅក្វាងជូ

| តំបន់ | ឈ្មោះមជ្ឈមណ្ឌលថែទាំកុមារ | សង្កាត់ | អាសយដ្ឋាន | លេខទូរស័ព្ទ | សម្គាល់ |
|---|---|---|---|---|---|
| ខណ្ឌក្វាងសាន់ | 국공립해솔빛어린이집 | សង្កាត់អ៊ូសាន់ | 광산구 무진대로 276 | 062-945-4235 | ឯកទេស |
| | (사)엠마우스어린이집 | សង្កាត់រ៉ំលគុក២ | 광산구 산정공원로71번길 32-9 | 062-955-7701 | ឯកទេស |
| | 국공립해맑은어린이집 | សង្កាត់អរ៉ុង | 광산구 소촌로42번길 11-14 | 062-945-3050 | ឯកទេស |
| ខណ្ឌដុងគូ | (민간)푸르른어린이집 | សង្កាត់ណេណាម | 동구 남계길 29 | 062-227-0810 | ឯកទេស |
| | (사)해냄어린이집 | សង្កាត់ហាក់ដុង | 동구 증심천로 120 | 062-524-7004 | ឯកទេស |
| ខណ្ឌសគូ | (사)아름어린이집 | សង្កាត់ក្វាងឆន់ | 서구 천변좌하로660번길 2-9 | 062-368-3200 | ឯកទេស |
| | (사)금부어린이집 | សង្កាត់គឹមហូ | 서구 금호운천길 54-1 | 062-375-3686 | ឯកទេស |
| ខណ្ឌណាមគូ | (사)무지개어린이집 | សង្កាត់ជីសក់ | 남구 고싸움로164번길 19-1 | 062-374-7117 | ឯកទេស |
| | (민간)우리무지개어린이집 | សង្កាត់ជីសក់ | 남구 고싸움로164번길 19-11 | 062-374-7118 | ឯកទេស |
| | 국공립효사랑하나어린이집 | សង្កាត់រ៉ំលសាន់៥ | 남구 대남대로308번길 33 | 062-433-2020 | ឯកទេស |
| | 남구구립늘봄어린이집 | សង្កាត់ហ៊ឹមអាម | 남구 효천중앙로 21 | 062-710-1100 | ទូទៅ |
| | 남구구립아이꿈어린이집 | សង្កាត់ហ៊ឹមអាម | 남구 효천로 176동, 광주효천LH1단지 | 062-672-5316 | ទូទៅ |
| ខណ្ឌប៊ុកគូ | 국공립그린빛어린이집 | សង្កាត់ឃូដុង | 북구 서림로 153, 금남로대광로제비앙 | 062-716-6888 | ទូទៅ |
| | 국공립꿈모아어린이집 | សង្កាត់អ៊ូនណាម | 북구 서강로 171, 중외공원 모아미래도 | 062-523-7179 | ទូទៅ |
| | 국공립리채아이어린이집 | សង្កាត់យ៉ុងឌូ | 북구 용두마을2길 12, 첨단진아리채 아파트 | 062-412-0333 | ទូទៅ |
| | 국공립센트럴파크어린이집 | សង្កាត់កាកហ្វា | 북구 동문대로249번길 19, 각화센트럴파크서희 | 062-266-7942 | ទូទៅ |
| | 국공립힐스테이트야호어린이집 | សង្កាត់បុនឈុន | 북구 본촌마을길 157-22, 힐스테이트본촌 | 062-575-0708 | ទូទៅ |
| | 국공립중흥하나어린이집 | សង្កាត់ជូងហ៊ឹង | 북구 우치로40번길 18 | 062-521-8925 | ទូទៅ |
| | (사)희망어린이집 | សង្កាត់យ៉ុងបុង | 북구 용주로40번길 87 | 062-526-3788 | ទូទៅ |
| | (사)밀알특수어린이집 | សង្កាត់បុនឈុន | 북구 본촌마을길 183 | 062-574-2133 | ឯកទេស |

→ មជ្ឈមណ្ឌលថែទាំកុមារពិការពិសេស៖ មជ្ឈមណ្ឌលថែទាំកុមារដែលបំពាក់ដោយឧបករណ៍សម្រាប់ថែទាំទារក និងកុមារពិការចាប់ពី១២នាក់ឡើងទៅ

→ មជ្ឈមណ្ឌលថែទាំកុមារពិការរួមបញ្ចូលគ្នា៖ មណ្ឌលថែទាំកុមារ និងកុមារពិការចាប់ពីបីនាក់ឡើង



# 05 ការអប់រំ និងសុខុមាលភាព

## 1. ការអប់រំ និងការចូលរៀនរបស់កុមារ

### ព័ត៌មានពីការចូលរៀនរបស់សិស្សក្នុងគ្រួសារពហុវប្បធម៌

**នីតិវិធីចូលរៀន (បឋមសិក្សា)** នៅក្នុងខែ១២ មជ្ឈមណ្ឌលតាមសង្កាត់ នឹងផ្ញើលិខិតប្រកាសការចូលរៀន
ចូលរួមនៅថ្ងៃប្រជុំបឋមនៅចុងខែ១ឬដើមខែ២( ភ្ជាប់ជាមួយលិខិតប្រកាសការចូលរៀន )។
ចូលរួមពិធីបើកបវេសនកាល នៅដើមខែ៣។
**(អនុវិទ្យាល័យ·វិទ្យាល័យ)** ឆែកព័ត៌មាននៅគេហទំព័រមន្ទីរអប់រំទីក្រុងក្វាងជូ និងព័ត៌មានចូលរៀននៅវិទ្យាល័យ ( www.hishool.go.kr )

### ព័ត៌មានអំពីវិធីសាស្ត្រផ្ទេរសាលាសម្រាប់សិស្សបឋមសិក្សា មធ្យមសិក្សា និងវិទ្យាល័យសម្រាប់គ្រួសារពហុវប្បធម៌

**របៀបផ្ទេរសាលា**

សាលាបឋមសិក្សា៖ ជូនដំណឹងដល់គ្រូបន្ទុកថ្នាក់អំពីការផ្ទេរសាលាពីរសប្តាហ៍ជាមុន → បន្ទាប់ពីផ្លាស់ទៅលំនៅដ្ឋានថ្មី រាយការណ៍ការផ្លាស់ទីលំនៅទៅមជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលសង្កាត់ ហើយដាក់ពាក្យសុំចូលសាលាបឋមសិក្សា ( ផ្ទេទៅសាលាដែលនៅជិតផ្ទះ ) → ទទួល លិខិតបញ្ជាក់ផ្លាស់ទីលំនៅសម្រាប់ដាក់ជូនសាលាផ្ទេរទៅ
→ សាលាមធ្យមសិក្សា → ( ការផ្ទេរសាលានៅតំបន់ដដែល ) ជូនដំណឹងដល់គ្រូបន្ទុកថ្នាក់អំពីការផ្ទេរសាលាពីរសប្តាហ៍ជាមុន ( ប្រគល់កិច្ចសន្យាជួលផ្ទះដែលនឹងផ្លាស់ទៅ ) → ពិនិត្យស្ថានភាពទំនេរនៅសាលាមធ្យមសិក្សានៅជិតលំនៅដ្ឋានថ្មី ( ទូរស័ព្ទទៅមន្ទីរអប់រំ ឬសាលាមធ្យមសិក្សាដើម្បីសាកសួរ ) → បន្ទាប់ពីរាយការណ៍ផ្លាស់ទីលំនៅទៅដល់មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលសង្កាត់ហើយ និងធ្វើលិខិតចុះឈ្មោះស្នាក់នៅថ្មី → ប្រគល់លិខិតចុះឈ្មោះស្នាក់នៅថ្មីសាលាបច្ចុប្បន្ន និងធ្វើលិខិតបញ្ជាក់ការសិក្សាមួយ សម្រាប់ផ្ទេរសាលារៀន → ទៅមើលសាលាដែលត្រូវផ្ទេរទៅ ហើយប្រគល់លិខិតចុះឈ្មោះស្នាក់នៅថ្មី និងលិខិតបញ្ជាក់ការសិក្សា
→ ( ផ្ទេរទៅទីក្រុង/ខេត្តផ្សេងទៀត ) ជូនដំណឹងដល់គ្រូបន្ទុកថ្នាក់អំពីការផ្ទេរសាលាពីរសប្តាហ៍ជាមុន → បន្ទាប់ពីរាយការណ៍ផ្លាស់ទីលំនៅទៅដល់មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលសង្កាត់ហើយ និងធ្វើលិខិតចុះឈ្មោះស្នាក់នៅថ្មី
→ ទៅកាន់មន្ទីរគាំទ្រការអប់រំ ដែលមានសមត្ថកិច្ចលើលំនៅឋានថ្មី និងប្រគល់ឯកសារ( ទម្រង់ពាក្យសុំផ្ទេរ លិខិតចុះឈ្មោះស្នាក់នៅថ្មី លិខិតបញ្ជាក់ការសិក្សាមួយ សម្រាប់ផ្ទេរសាលារៀន លិខិតបញ្ជាក់ពីការផ្លាស់ប្តូរទីលំនៅ )
→ ទៅសាលានឹងផ្ទេរ ហើយចុះឈ្មោះ → វិទ្យាល័យ៖ ការផ្ទេរវិទ្យាល័យអាចមានភាពស្មុគស្មាញ ដូច្នេះត្រូវទាក់ទង និងសាកសួរទៅគ្រូបន្ទុកថ្នាក់ និងមន្ទីរអប់រំក្រុងក្វាងជូ

※ ការផ្ទេរ មធ្យមសិក្សា និងវិទ្យាល័យ ឪពុកម្តាយមិនអាចជ្រើសរើសបានទេ លុះត្រាសាលានោះមានកន្លែងទំនេរ ។ ម៉្យាងទៀត ប្រសិនបើសិស្សសាលាមធ្យមសិក្សាឆ្នាំទី៣ត្រូវផ្ទេរសាលា ការផ្ទេរគឺអាចធ្វើទៅបានរហូតដល់កាលបរិច្ឆេទ នៃការប្រកាសចូលរៀននៅវិទ្យាល័យ ( ជាធម្មតានៅថ្ងៃខែតុលា )

※ ក្នុងករណី កូនរបស់គ្រួសារជនបរទេស ឬក្មេងដែលទើបចូលប្រទេសកូរ៉េ ត្រូវផ្ទេរសាលា ត្រូវការឯកសារផ្សេងទៀតដូចជា លិខិតបញ្ជាក់ការចេញចូលប្រទេសកូរ៉េ ឬលិខិតបញ្ជាក់ចុះឈ្មោះជនបរទេស ( ប្រសិនមិនអាចប្រគល់ឯកសារទាំងនេះ អាចប្រគល់ឯកសារបញ្ជាក់ពីលំនៅដ្ឋាន ដូចជាកិច្ចព្រមព្រៀងជួលផ្ទះជាដើម ), ព្រឹត្តិបត្តិពិន្ទុឆ្នាំមុន និងលិខិតបញ្ជាក់ការសិក្សាពីសាលាបរទេស ( ទាមទារការបញ្ជាក់ដោយស្ថានទូត ) វិញ្ញាបនបត្រចាក់ថ្នាំបង្ការជាដើម។

## ការចូលរៀនរបស់កូននៃគ្រួសារជនបរទេស( សញ្ជាតិបរទេស )

**អាយុចូលរៀន** កុមារដែលមានអាយុត្រឹម៦ឆ្នាំ គិតដល់ថ្ងៃទី៣១ ខែធ្នូ មានកាតព្វកិច្ចចូលរៀននៅបឋមសិក្សានៅខែ៣ឆ្នាំបន្ទាប់។

**នីតិវិធីចូលរៀន** ចំពោះកុមារនៃគ្រួសារជនបរទេសដែលកើតនៅកូរ៉េ នឹងមិនទទួលបានសេចក្តីប្រកាសចូលរៀននោះទេ។ ក្នុងករណីនេះ សូមទៅបឋមសិក្សាដែលនៅជិត ហើយពិគ្រោះយោបល់ពីការចូលរៀន ដោយភ្ជាប់ជាមួយឯកសារបញ្ជាក់ការស្នាក់នៅក្នុងប្រទេសកូរ៉េ។ ចំពោះជនបរទេសដែលមិនចុះឈ្មោះក្នុងបញ្ជី ក៏អាចចូលរៀនបានដែរ សូមរៀបចំ កិច្ចសន្យាជួលផ្ទះ លិខិតធានា ដែលអាចបញ្ជាក់ទីលំនៅ និងឆ្នាំកំណើតរបស់កូន។

**លេខទូរស័ព្ទ** សាលារៀនដែលនៅជិតទីស្នាក់នៅ, ក្រុមអប់រំពហុវប្បធម៌ មន្ទីរអប់រំក្រុងក្វាងជូ( ☎ 062-940-8954 )

## 2. ព័ត៌មានអប់រំសម្រាប់យុវជនអន្តោប្រវេសន៍

### ព័ត៌មានទាក់ទងសាលារ៉េនបូ សម្រាប់យុវជនចូលប្រទេសកូរ៉េតាមក្រោយ

**គោលដៅ៖** យុវជនដែលចូលប្រទេសកូរ៉េតាមក្រោយ មានអាយុចាប់ពី៩ឆ្នាំ ដល់២៤ឆ្នាំ
- មិនគិតពីសញ្ជាតិ និងសិទ្ធិរស់នៅក្នុងប្រទេសកូរ៉េ

**រយៈពេលសិក្សា៖** ២០២៣. ៣. ៦.~១១. ១២./ ៥ថ្ងៃក្នុងមួយសប្តាហ៍( ច័ន្ទ ~ សុក្រ ) ម៉ោង ១៣:០០ ដល់ម៉ោង ១៥:០០

**ខ្លឹមសារការសិក្សា៖** ថ្នាក់អប់រំភាសាកូរ៉េ ថ្នាក់អប់រំឯកទេសពិសេស ( ប្រធានបទ, មុខវិជ្ជាសាលា, ការអប់រំឯកទេសអាជីព )

**តម្លៃសិក្សា៖** មិនមានការបង់ប្រាក់( មិនរាប់បញ្ចូលសម្ភារៈផ្សេងៗ )

**របៀបចុះឈ្មោះ៖** បំពេញពាក្យស្នើសុំបន្ទាប់ពីជួប និងប្រឹក្សាយោបល់

**រយៈពេលចុះឈ្មោះ៖** គ្រប់ពេល

**ទូរស័ព្ទសាកសួរ៖** មជ្ឈមណ្ឌលគ្រួសារប៊ុកគូ ក្រុងក្វាងជូ ( ☎ 062-526-6004 )

### សេចក្តីណែនាំពីការចូលរៀនសម្រាប់យុវជនដែលចូលប្រទេសកូរ៉េតាមក្រោយ

**ឯកសារចាំបាច់** ពាក្យសុំចូលរៀនឬផ្លាស់មករៀន, លិខិតបញ្ជាក់សិក្សារ( ឬបញ្ចប់ការសិក្សា )របស់ប្រទេសកំណើត, ព្រឹត្តិបត្តិពិន្ទុ, លិខិតអន្តោប្រវេសន៍, ឯកសារបញ្ជាក់ការទីលំនៅក្នុងស្រុក, លិខិតចុះឈ្មោះជនបរទេស ( លិខិតបញ្ជាក់ទំនាក់ទំនងគ្រួសារ,លិខិតបញ្ជីអ្នកស្នាក់នៅ ), លិខិតបញ្ជាក់ចាក់ថ្នាំបង្ការ។

**លេខទូរស័ព្ទ** សាលារៀនដែលនៅជិតទីស្នាក់នៅ, ក្រុមអប់រំពហុវប្បធម៌ មន្ទីរអប់រំក្រុងក្វាងជូ( ☎ 062-380-4365 )

### ស្ថាប័នអប់រំទទួលបន្ទុកសិស្សបរទេស និងសិស្សចូលប្រទេសប្រទេសកូរ៉េតាមក្រោយ

| ឈ្មោះសាលា | កម្រិតបើកបង្រៀន | អាស័យដ្ឋាន | លេខទូរស័ព្ទ |
|---|---|---|---|
| សាលា ស៊ែណាល | កម្មវិធីសិក្សាបញ្ចូលគ្នា អនុវិទ្យាល័យ ( ៣ថ្នាក់ ), វិទ្យាល័យ( ៣ថ្នាក់ ) | ទីក្រុងក្វាងជូ ក្វាងសានហ្គូ ផ្យង់ដុងរ៉ូ២៩ | ☎ 062-943-8935 |

### គេហទំព័រព័ត៌មានគាំទ្រសម្រាប់សិស្សបរទេស និងសិស្សចូលប្រទេសកូរ៉េតាមក្រោយ

**មជ្ឈមណ្ឌលអប់រំពហុវប្បធម៌ជុងអាង** https://www.edu4mc.or.kr

**មជ្ឈមណ្ឌលយុវជនឥណ្ឌធនូ** http://www.rainbowyouth.or.kr



## 3. ស្ថានភាពសាលាពិសេសនៅក្វាងជូ

### ស្ថានភាពនៃសាលាពិសេស

| តំបន់ | ឈ្មោះសាលា | ប្រភេទពិការភាព | ចំនួនកម្រិតថ្នាក់ | | | | | | អាសយដ្ឋាន | លេខទូរស័ព្ទ | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទារក | កុមារ | បឋម | មធ្យម | វិទ្យាល័យ | ជំនាញ | | | |
| ខណ្ឌក្វាងសាន់ | 광주선광학교 | ខ្សោយបញ្ញា | 2 | 1 | 21 | 19 | 17 | 4 | 광산구 목련로 394번길 60-3 | ☎062-950-9107 | រដ្ឋ |
| ខណ្ឌក្វាងសាន់ | 선예학교 | ខ្សោយបញ្ញា | 0 | 1 | 13 | 11 | 9 | 2 | 광산구 선암1로 7 | ☎062-570-7181 | រដ្ឋ |
| ខណ្ឌសគូ | 광주세광학교 | ចក្ខុវិញ្ញាណ | 2 | 3 | 8 | 4 | 6 | 4 | 서구 유덕로 177 | ☎062-606-0401 | ឯកជន |
| ខណ្ឌណាមគូ | 광주선명학교 | ខ្សោយបញ្ញា | 1 | 1 | 18 | 12 | 7 | 4 | 남구 서문대로749번마길 2 | ☎062-650-9746 | រដ្ឋ |
| ខណ្ឌប៊ុគូ | 광주선우학교 | ខ្សោយបញ្ញា | 2 | 2 | 18 | 12 | 10 | 4 | 북구 모룡대길 61 | ☎062-712-6900 | រដ្ឋ |
| ខណ្ឌប៊ុគូ | 광주선우학교 | សោតវិញ្ញាណ | 0 | 0 | 1 | 2 | 3 | 0 | 북구 모룡대길 61 | ☎062-712-6900 | រដ្ឋ |
| ខណ្ឌប៊ុគូ | 은혜학교 | សារពាង្គកាយ | 0 | 1 | 21 | 8 | 10 | 0 | 북구 앰코로 127 | ☎062-970-9860 | ឯកជន |

### ស្ថានភាពនៃថ្នាក់ពិសេស

| វគ្គសិក្សា | មន្ទីរអប់រំ | ឈ្មោះសាលា ( ចំនួនកម្រិតថ្នាក់ ) |
|---|---|---|
| មត្តេយ្យ | មន្ទីរអប់រំដុងប៊ូ ( ខណ្ឌប៊ុកគូ, ខណ្ឌដុងគូ ) | 광주학운초병설유(1), 광주효동초병설유(1), 광주서산초병설유(2), 광주양산초병설유(1) 정덕유(1), 신용유(1), 건국유(1), 지한유(1), 새미르유(1), 삼각초병설(1),한울초병설(1) |
| មត្តេយ្យ | មន្ទីរអប់រំសប៊ូ ( ខណ្ឌក្វាងសាន់, ខណ្ឌណាមគូ, ខណ្ឌសគូ ) | 광주광천초병설유(1), 새별초병설유(1), 성진초병설유(1), 불로초병설유(1), 봉산유(1), 진남유(1), 예향유(2), 빛고을유(1), 화운유(1), 방림유(1), 효천다솜유(2), 광주극락초병설유(1), 수완초병설유(1), 대촌중앙초병설유(1), 송정서초병설유(1) |
| បឋម | មន្ទីរអប់រំដុងប៊ូ | 교대부설(1), 광주서석(1), 광주계림(2), 광주서림(1), 광주효동(3), 광주남(2), 광주동(1), 광주지산(1), 광주서산(1), 광주동산(2), 광주양산(2), 광주중흥(2), 광주산수(1), 광주문화(2), 광주장원초(1), 광주학운(2), 광주동운(1), 광주용봉(1), 광주풍향,(1) 광주운암(1), 광주우산(1), 경양초(1), 무등(2), 광주용산(1), 각화(1), 태봉(2), 대자(1), 문흥(1), 오치(2), 삼정(1), 문흥중앙(1), 율곡(1), 문산(1), 오정(1), 매곡(1), 일곡(1), 삼각(1), 동림(2), 서일(1), 용두(2), 일동(1), 용주(1), 문우(1), 본촌(1), 연제(2), 양지(2), 한울(1), 신용(4), 건국(2), 광주북(1), 지한(1) |

| វគ្គសិក្សា | មន្ទីរអប់រំ | ឈ្មោះសាលា ( ចំនួនកម្រិតថ្នាក់ ) |
|---|---|---|
| បឋម | មន្ទីរអប់រំសប៊ូ | 광주대성(1), 광주학강(1), 광주양동(1), 광주극락(1), 광주효덕(1), 광주백운(1), 광주방림(2), 광주월산(1), 광주상무(1), 광주광천(2), 광주농성(1), 광주화정(1), 광주봉주(2), 광주서(2), 주월(1), 봉선(1), 염주(1), 서광(2), 장산(2), 광주제석(1), 효광(1), 성진(1), 화정남(1), 진월(1), 금호(2), 송정동(1), 송정서(1), 송정중앙(2), 송정(2), 송우(2), 비아(1), 산월(2), 하남(2), 하남중앙(1), 월곡(2), 어등(2), 임곡(1), 평동(1), 금부(2), 삼도(1), 풍암(1), 대촌중앙(1), 목련(1), 송학(1), 월계(1), 정암(1), 운남(2), 운천(1), 미산(1), 유덕(1), 화개(1), 금당(1), 마재(1), 금구(1), 평(1), 마지(1), 신암(1), 진만(1), 풍영(1), 계수(1), 운리(1), 대반(1), 첨단(1), 어룡(2), 봉산(1), 영천(1), 월봉(1), 신창(1), 선창(2), 만호(1), 도산(1), 진남(1), 수완(1), 고실(1), 장덕(2), 큰별(1), 성덕(1), 빛고을(1), 광림(1), 선운(2), 은빛(1), 새별(1), 효천(2), 유안(1), 빛여울(1) |
| មធ្យមសិក្សា | មន្ទីរអប់រំដុងប៊ូ | 전대사대부중(1), 광주충장중(2), 무등중(1), 운림중(1), 운암중(3), 우산중(1), 용봉중(1), 신광중(1), 문화중(1), 두암중(1), 각화중(1), 문흥중(1), 양산중(1), 일곡중(1), 일동중(1), 지산중(1), 용두중(1), 신용중(1), 광주동신중(1), 광주북성중(1) |
| | មន្ទីរអប់រំសប៊ូ | 광주무진중(1), 봉선중(2), 상무중(1), 광주서광중(1), 광주효광중(1), 광주화정중(2), 광주중(1), 주월중(1), 금당중(2), 송정중(2), 광산중(1), 상일중(1), 하남중(1), 월곡중(1), 금호중(1), 월계중(1), 운남중(1), 광주동명중(1), 풍암중(1), 금구중(1), 천곡중(1), 전남중(1), 송광중(2), 영천중(1), 신가중(1), 운리중(1), 신창중(1), 유덕중(1), 월봉중(2), 수완중(1), 진남중(2), 산정중(1), 장덕중(1), 대자중(1), 선운중(1), 수완하나중(1), 효천중(1), 고실중(1), 정광중(1) |
| វិទ្យាល័យ | មន្ទីរអប់រំដុងប៊ូ | 전대사대부고(2), 광주고(2), 광주제일고(2), 전남여고(1), 광주자연과학고(4), 광주공고(1), 문정여고(1), 빛고을고(2), 조대부고(1), 광주수피아여고(2), 숭의과학기술고(2) |
| | មន្ទីរអប់រំសប៊ូ | 전남고(1), 광주여고(2), 광주전자공고(4), 상무고(3), 운남고(3), 풍암고(3), 첨단고(2), 상일여고(1), 장덕고(1), 수완고(2), 정광고(2), 명진고(2) |

## ព័ត៌មានស្តីពីការគាំទ្រការអប់រំដោយឥតគិតថ្លៃ និងជាកំហិតសម្រាប់មុខវិជ្ជាអប់រំពិសេស ( កុមារដែលមានការអភិវឌ្ឍន៍យឺត )

① ការគាំទ្រការអប់រំដោយឥតគិតថ្លៃសម្រាប់សិស្សទទួលការអប់រំពិសេស

**បុគ្គលដែលអាចទទួលជំនួយ៖ កុមារអាយុក្រោម ៣ឆ្នាំដែលត្រូវបានជ្រើសរើសក្នុងការទទួលការអប់រំពិសេស**

**ជំនួយដែលអាចទទួលបាន៖**

ការបញ្ជូនកុមារដែលត្រូវទទួលការអប់រំពិសេស ទៅស្ថាប័នអប់រំពិសេស និងធ្វើការអប់រំ

- ចុះតាមផ្ទះដើម្បីផ្តល់ការអប់រំផ្ទាល់ខ្លួន និងណែនាំអំពីទម្លាប់នៃការរស់នៅជាមូលដ្ឋាន
  ជំនួយសេវាកម្មទាក់ទងនឹងការអប់រំពិសេស
- ការប្រឹក្សាគ្រួសារ ការអប់រំមាតាបិតា ការចំណាយលើការព្យាបាល ជំនួយឧបករណ៍បច្ចេកវិទ្យា។ល។

② ជំនួយសម្រាប់ការអប់រំជាកំហិតសម្រាប់មុខវិជ្ជាអប់រំពិសេស

**បុគ្គលដែលអាចទទួលជំនួយ៖** កុមារអាយុពី ៣ទៅ៥ឆ្នាំដែលត្រូវបានជ្រើសរើសក្នុងការទទួលការអប់រំពិសេស សិស្សបឋមសិក្សា មធ្យមសិក្សា និងវិទ្យាល័យដែលត្រូវបានជ្រើសរើសទទួលការអប់រំពិសេស



**ជំនួយដែលអាចទទួលបាន៖**

- ការអប់រំពិសេសផ្តល់នៅតាមមត្តេយ្យ បឋមសិក្សា មធ្យមសិក្សា វិទ្យាល័យ និងសាលាពិសេស
- ការអប់រំផ្ទាល់ខ្លួន និងការណែនាំអំពីរបៀបរស់នៅជាមូលដ្ឋាន
- សាលារៀនដែលមិនមានថ្នាក់ពិសេស នឹងចុះទៅតាមផ្ទះ និងផ្តល់ការអប់រំ
- ជំនួយសេវាកម្មទាក់ទងនឹងការអប់រំពិសេស
- ការប្រឹក្សាគ្រួសារ ការអប់រំមាតាបិតា ការចំណាយលើការព្យាបាល ជំនួយឧបករណ៍បច្ចេកវិទ្យា។ល។

**សាកសួរព័ត៌មាន៖** មន្ទីរគាំទ្រការអប់រំក្វាងជូសប៊ូ មជ្ឈមណ្ឌលគាំទ្រការអប់រំពិសេស ( ☎ 062-600-9632 )
មន្ទីរគាំទ្រការអប់រំក្វាងជូដុងប៊ូ មជ្ឈមណ្ឌលគាំទ្រការអប់រំពិសេស ( ☎ 062-605-5741 )

## 4. ប្រព័ន្ធសុខុមាលភាពផ្សេងទៀត

### សេវាកម្មជួយបង្កើត ឬកែឈ្មោះរបស់ជនរៀបការអន្តោប្រវេសន៍ដែលបានចូលសញ្ជាតិ

**រយៈពេលស្នើសុំ** ពេលណាក៏បាន។

**គុណសម្បត្តិដើម្បីស្នើសុំ** ជនរៀបការអន្តោប្រវេសន៍ដែលចង់កែឈ្មោះត្រកូល បន្ទាប់ពីទទួលបានសញ្ជាតិកូរ៉េ និងមានចំណូលមធ្យមក្រោម១២៥% រស់នៅខណ្ឌហ្វាង់សាន។

**ខ្លឹមសារនៃការគាំទ្រ** ចុះឈ្មោះកែឬបង្កើតនាមត្រកូលដោយឥតគិតថ្លៃ។

**ឯកសាររៀបចំ** លិខិតបញ្ជាក់មូលដ្ឋាន( លម្អិត ), លិខិតទំនាក់ទំនងគ្រួសារ( លម្អិត ), លិខិតអាពាហ៍ពិពាហ៍, លិខិតបង់ថ្លៃសេវាធានារ៉ាប់រងសុខភាព, លិខិតបញ្ជាក់( ជូនដំណឹង )សុពលភាពធានារ៉ាប់រងសុខភាព លិខិតចុះឈ្មោះអ្នកស្នាក់នៅ ១ច្បាប់, ត្រា( មុនកែឈ្មោះ )

*លិខិតបញ្ជាក់សុពលភាពធានារ៉ាប់រងសុខភាព( ៣ខែចុងក្រោយ )៖ បើស្វាមី និងភរិយាមានធានារ៉ាប់រងផ្សេងគ្នា ត្រូវប្រគល់លិខិតទាំងពីរ

*លិខិតបញ្ជាក់សុពលភាពធានារ៉ាប់រងសុខភាព៖ ត្រូវមានសមាជិកគ្រួសារទាំងអស់ក្នុងឯកសារ

**កន្លែងស្នើសុំ** សាលាខណ្ឌក្វាងសាន់ ផ្នែកជនបរទេស ក្រុមគាំទ្រជនបរទេស

**លេខទូរស័ព្ទ** សាលាខណ្ឌក្វាងសាន់ ផ្នែកជនបរទេស ក្រុមគាំទ្រជនបរទេស( ☎ 062-960-4135 )

### គ្រួសារដែលមានចំណូលទាប និងមានឪពុកម្តាយតែមួយ ( ជនអន្តោប្រវេសន៍រៀបការ )

**គោលដៅ ៖** ជនបរទេសបានចុះឈ្មោះ និងចិញ្ចឹមកូនមានសញ្ជាតិកូរ៉េ( អាយុក្រោម ១៨ឆ្នាំ ) តែម្នាក់ឯង ដោយសារការលែងលះ ការបែកគ្នា ឬការបោះបង់ -ល- និងមានប្រាក់ចំណូលជាមធ្យមតិចជាង៥២%

**វិធីផ្តល់ជំនួយ៖** ឧបត្ថម្ភដល់កុមារដែលត្រូវបានជ្រើសរើសជាគ្រួសារដែលមានសិទ្ធិ ចាប់ពីខែនៃការដាក់ពាក្យទៅ

**ជំនួយផ្នែក៖** ការចំណាយសម្រាប់កុមារ, ការចំណាយបន្ថែមសម្រាប់កុមារ, សម្ភារៈសិក្សាសម្រាប់សិស្ស អនុវិទ្យាល័យ និងវិទ្យាល័យ ,ប្រាក់ឧបត្ថម្ភការរស់នៅ។ល។

**របៀបចុះឈ្មោះ៖** ដាក់ពាក្យស្នើសុំ បន្ទាប់ពីជួបពិគ្រោះយោបល់ជាមួយបុគ្គលិកនៅមជ្ឈមណ្ឌលសុខុមាលភាពសុភមង្គលដែលមាននៅតាមសង្កាត់

**ទូរស័ព្ទសាកសួរ៖** ក្រុមគោលនយោបាយមិត្តភាពស្ត្រី ផ្នែកស្ត្រីនិងកុមារ ក្វាងសានគូ( ☎ 062-960-8383 ), ទូរស័ព្ទពិគ្រោះយោបល់សម្រាប់គ្រួសារមានតែឪពុក ឬម្តាយ( ☎ 1644-6621 )

## ប្រព័ន្ធទ្រទ្រង់សុខុមាលភាពករណីបន្ទាន់

**គោលការប្រព័ន្ធ៖** ប្រព័ន្ធនេះផ្តល់ការគាំទ្រជាបណ្តោះអាសន្ន នៅពេលមានការលំបាកក្នុងការរកចំណូលសម្រាប់ចំណាយក្នុងជីវភាព ដោយសារវិបត្តិភ្លាមៗ។ ទៅដល់ជនក្រីក្រ( ទាបជាង ៧៥% នៃប្រាក់ចំណូលមធ្យម ), ជនបរទេសដែលបានចុះឈ្មោះ ( មិនរួមបញ្ចូលភ្ញៀវទេសចរ ) ក៏អាចទទួលបានអត្ថប្រយោជន៍នេះផងដែរ ដែលបានកំណត់ដោយច្បាប់។

* ៧៥% នៃប្រាក់ចំណូលមធ្យមស្តង់ដារ ( ១,៦៧០,០០០វ៉ុន សម្រាប់មនុស្សម្នាក់, ៤,៣០០,០០០ វ៉ុន សម្រាប់គ្រួសារសមាជិក៤នាក់ )

**ផ្តោតលើ៖** គ្រួសារដែលមានចំណូលទាប មានលក្ខខណ្ឌមូលហេតុដូចជាវិបត្តិប្រាក់ចំណូល និងស្តង់ដារអចលនទ្រព្យជាដើម និងបុគ្គលដែលត្រូវទៅនឹងលក្ខខណ្ឌខាងក្រោមដូចជា៖

① ជនរៀបការជាមួយនឹងជនជាតិកូរ៉េ

② ជនបានលែងលះជាមួយប្តី ឬប្រពន្ធជនជាតិកូរ៉េ ឬស្លាប់ និងត្រូវថែរក្សាពូជពង្សជាសញ្ជាតិកូរ៉េ

③ ជនទទួលស្គាល់ជាជនភៀសខ្លួន

④ ជនរងគ្រោះដោយអគ្គិភ័យ ឧក្រិដ្ឋកម្ម គ្រោះមហន្តរាយធម្មជាតិជាដើម ដែលមិនមែនជាកំហុសរបស់ខ្លួន។

⑤ ក្រៅពីនេះទៀត ជនដែលត្រូវចាត់ទុកថាចាំបាច់ត្រូវទទួលបានជំនួយបន្ទាន់ ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសុខុមាលភាព

**ជំនួយផ្នែក៖** ការចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃ, ផ្នែកវេជ្ជសាស្ត្រ ការចំណាយលើលំនៅដ្ឋាន -ល-

**កន្លែងចុះឈ្មោះ៖** ការិយាល័យរដ្ឋបាល មជ្ឈមណ្ឌលសុខុមាលភាពក្នុងសង្កាត់( Dong )

**ទូរស័ព្ទសាកសួរ៖** ក្រុមសុខុមាលភាព ផ្នែកគោលនយោបាយសុខុមាលភាព ក្វាងសានគូ( ☎ 062-960-8398, 8405 ( ផ្នែកវេជ្ជសាស្ត្រ ),ទូរស័ព្ទក្រសួងសុខាភិបាល( ☎ 129 )

## ស្នើសុំចុះឈ្មោះជនបរទេស និងជនជាត់កូរ៉េកាន់សញ្ជាតិបរទេស ជាជនពិការ

**គោលដៅ** ជនជាតិកូរ៉េមានសញ្ជាតិបរទេស( F-4 ), ជនមានសិទ្ធិរស់នៅអចិន្ត្រៃ( F-5 ), ជនរៀបការអន្តោប្រវេសន៍ ( F-6 ), ជនដែលទទួលស្គាល់ជាជនភៀសខ្លួន( F-2 ) ដែលកំណត់ថាមានពិការភាព។

**ឯកសារសម្រាប់សុំពាក្យ** លិខិតពិនិត្យពិការភាព, លទ្ធផលពិនិត្យ, កំណត់ហេតុព្យាបាល, អត្តសញ្ញាណបណ្ណ។ល។

**ទីកន្លែងសម្រាប់ពាក្យសុំ** មជ្ឈមណ្ឌលសង្គមកិច្ចនិងរដ្ឋបាលនៅសង្កាត់ដែលកំពុងស្នាក់នៅ។

**លេខទូរស័ព្ទ** ផ្នែកសុខុមាលភាពជនពិការ ក្រុមគោលនយោបាយជនពិការ ( ☎ 062-960-3840 )

## ព័ត៌មានណែនាំពីការលក់លំនៅដ្ឋានពិសេសសម្រាប់គ្រួសារពហុវប្បធម៌

**លក្ខណៈសម្បត្តិសម្រាប់ដាក់ពាក្យ** សមាជិកនៃគ្រួសារពហុវប្បធម៌ អនុលោមតាមមាត្រា ២ នៃ "ច្បាប់គាំទ្រគ្រួសារពហុវប្បធម៌" ដែលបានរស់នៅក្នុងអាសយដ្ឋានដូចគ្នាជាមួយប្តីឬប្រពន្ធរបយ៉ាងហោចណាស់៣ឆ្នាំ ហើយសមាជិកគ្រួសារបច្ចុប្បន្នទាំងអស់គ្មានកម្មសិទ្ធិលំនៅដ្ឋាន ។

※ សេចក្តីជូនដំណឹងស្តីពីការលក់លំនៅដ្ឋានពិសេស នឹងប្រកាសប្រហែលមួយខែមុនកាលបរិច្ឆេទនៃការប្រកាសលក់នៅលើគេហទំព័រសាជីវកម្មលំនៅដ្ឋានជាតិ។ៗ

**របៀបចុះឈ្មោះ៖** ត្រូវដាក់ពាក្យទៅកាន់អង្គភាពគម្រោងដែលពាក់ព័ន្ធ ស្របតាមកាលវិភាគជ្រើសរើសអ្នកស្នាក់នៅ សម្រាប់ផ្ទះដែលចង់ទិញ

**លេខទូរស័ព្ទ** សាជីវកម្មដីធ្លី និងលំនៅឋានកូរ៉េ( ☎ 1600-1004 )



## ការប្រឡងសមត្ថភាពសម្រាប់ជនរៀបការអន្តោប្រវេសន៍

**មុខវិជ្ជាប្រឡង** ភាសាកូរ៉េ,គណិតវិទ្យា, សង្គម, វិទ្យាសាស្ត្រ។

**កាលបរិច្ឆេទប្រឡង** ដូចគ្នានឹងការប្រឡងចូល អនុវិទ្យាល័យ វិទ្យាល័យ និងមហាវិទ្យាល័យ (២លើកក្នុង១ឆ្នាំ )។

**របៀបផ្សព្វផ្សាយ** ផ្សព្វផ្សាយតាមគេហទំព័រមន្ទីរអប់រំក្រុងក្វាងជូ

**លេខទូរស័ព្ទ** ក្រុមផ្តល់ដំណឹង ផ្នែកកិច្ចការទូទៅ មន្ទីរអប់រំក្រុងក្វាងជូ( ☎ 062-380-4125, 4052 )

## ខណ្ឌក្វាងសាន់ វិបផតថលសិក្សាពេញមួយជីវិត - បេអ៊ូរាងគេ

វេទិកា 'one-stop' ដែលអាចស្វែងរកយ៉ាងងាយស្រួល សម្រាប់ស្វែងរកព័ត៌មានអប់រំ និងដាក់ពាក្យចូលរៀន ដែលមានពាសពេញខណ្ឌក្វាងសាន់

គេហទំព័រ 배우랑께 https://edu.gwangsan.go.kr

**សេវាកម្មផ្តល់ជូន** (ការចែករំលែកព័ត៌មានអប់រំ) អាចពិនិត្យមើលព័ត៌មានអំពីកម្មវិធីអប់រំនៅខណ្ឌក្វាងសាន់នៅកន្លែងតែមួយ

-( ការចែករំលែកទីកន្លែង ) ការចែករំលែកព័ត៌មានទីកន្លែងដែលចាំបាច់សម្រាប់សកម្មភាពសិក្សា និងរៀនសូត្រ

- ( ចែករំលែកសកម្មភាពអ្នកបង្រៀន ) ពិនិត្យស្ថានភាពគ្រូបង្រៀនតាមផ្នែកផ្សេងៗ និងភ្ជាប់ជាមួយស្ថាប័ន

**សាកសួរព័ត៌មាន៖** ខណ្ឌក្វាងសាន់ ផ្នែកបណ្ណាល័យអប់រំ ក្រុមសិក្សាពេញមួយជីវិត ( ☎ 062-960-8285 )



# 06 ការងារ និងសុវត្ថិភាព

## 1. ព័ត៌មានអំពីការងារ

### ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ស្ត្រីអន្តោប្រវេសន៍អាពាហ៍ពិពាហ៍

**ជនដែលអាចចុះឈ្មោះ** ស្ត្រីអន្តោប្រវេសន៍អាពាហ៍ពិពាហ៍ ដែលបានចុះឈ្មោះស្វែងរកការងារ នៅមជ្ឈមណ្ឌលការងារថ្មីរបស់ស្ត្រី

**ឧបត្ថម្ភ** ផ្តល់ការអប់រំវិជ្ជាជីវៈ ដើម្បីពង្រឹងសមត្ថភាពការងាររបស់ស្ត្រីអន្តោប្រវេសន៍អាពាហ៍ពិពាហ៍

**របៀបចុះឈ្មោះ** ចុះឈ្មោះនៅ មជ្ឈមណ្ឌលការងារថ្មីរបស់ស្ត្រី ក្វាងជូ

**សាកសួរព័ត៌មាន** មជ្ឈមណ្ឌលការងារថ្មីរបស់ស្ត្រី ក្វាងជូ ( ☎ 1577-2919 )

### កាតពលរដ្ឋរៀនដើម្បីថ្ងៃស្អែក

**ជនដែលអាចចុះឈ្មោះ** ពលរដ្ឋដែលចង់បានការបណ្តុះបណ្តាលវិជ្ជាជីវៈ ( រួមទាំងជនអន្តោប្រវេសន៍អាពាហ៍ពិពាហ៍ និងយុវជនអន្តោប្រវេសន៍ )

※ មន្ត្រីសាធារណៈ បុគ្គលិកសាលាឯកជន និស្សិតដែលកំពុងសិក្សា( លើកលែងនិស្សិតដែលបម្រុងបញ្ចប់ការសិក្សា ) ម្ចាស់អាជីវកម្មផ្ទាល់ខ្លួនដែលមានចំណូលពីការលក់ប្រចាំឆ្នាំលើសពី១៥០លានវ៉ុន ជនដែលមានទិដ្ឋាការរយៈពេលខ្លី មិនមានសិទ្ធិចុះឈ្មោះទេ។

**រយៈពេលឧបត្ថម្ភ** ៥ឆ្នាំ ( ៥ឆ្នាំក្រោយ អាចចុះឈ្មោះម្តងទៀត )

**ឧបត្ថម្ភ** ផ្តល់ថ្លៃសិក្សាបណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈជា'កាតពលរដ្ឋរៀនដើម្បីថ្ងៃស្អែក' គិតជាទឹកប្រាក់ ចាប់ពី៣ទៅ៥លានវ៉ុន រយៈពេល៥ឆ្នាំ គិតចាប់ពីថ្ងៃបង្កើតគណនី។

**របៀបចុះឈ្មោះ** ( ចុះឈ្មោះយកកាត ) សូមមកកាន់មជ្ឈមណ្ឌលការងារ ដែលនៅជិតបំផុត ឬដាក់ពាក្យ តាមរយៈគេហទំព័របណ្តុះបណ្តាលវិជ្ជាជីវៈ www.hrd.go.kr

